ការសំភាសន៍របស់អ្នកមីង ជួប សម័យ

ក៖ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខ៖ អ្នកដែលត្រូវគេសំភាសន៍ ជួប សម័យ

<u>ការសង្ខេបរបស់អ្នកមីង ជួប សម័យ</u>

អ្នកមីងជួប សម័យ
គាត់មានបងប្អូន២នាក់ហើយគាត់កើតបាន១០ឆ្នាំទើបម្តាយមានកូនម្នាក់ទៀត
ហើយពេលប្អូនគាត់កើតក្នុងរបបប៉ុល ពត
។អ្នកមីងគាត់ស្រលាញ់ប្អូនរបស់គាត់ហើយតាំងពីគាត់ដឹងក្តីមកគឺឪពុកម្តាយគាត់បានធ្វើការ
នៅក្នុងរោងចក្រធ្វើតាំងហ៊ុន គឺមីសូរហើយគាត់ពុំសូវមានពេលច្រើនជាមួយឪពុកគាត់ទេ
ហើយគាត់បានជិតស្និតនឹងលោកតារបស់គាត់
ហើយពួកគាត់គឺជាអ្នកស្រុកស្អាងនៅស្វាយរលំ។

ក៖
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្ន
កមីង នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនៅក្នុងថ្ងៃនេះ
ពួកយើងសំភាសន៍គឺនៅក្នុងខែមិនា ឆ្នាំ២០១៨ ការសំភាសន៍មានទីតាំងស្ថិតនៅក្នុងភូមិ
អើរភូមិអីគេមីង?

ខ៖ ភូមិស្វាយរលំ។

ក៖ នៅភូមិស្វាយរលំ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល។ត្រូវហើយណោះមីងណោះ?

ខ៖ ចា!!ភូមិលេខមួយ។

ក៖ ភូមិលេខមួយ!!អ៊ីចឹងអ្នកមីង!អ៊ីចឹងការសំភាសន៍ញ៉ុមសូមសួរអ្នកមីងដូចតទៅ
អ្នកមីងសូមប្រាប់ឈ្មោះពេញមើលឈ្មោះអីគេដែរ?

ខ៖ នាងខ្ញុំឈ្មោះ ជួប សម័យ។

ក៖ ក្រៅពីឈ្មោះជួប សម័យមីងមានឈ្មោះអីគេផ្សេងទៀតទេ?

ខ៖ អត់មានទេ។

ក៖ នៅពីក្មេងម៉ែឪមានដាក់ងារអីអោយទេ?

ខ៖ អត់ទេ!!

ក៖ អត់មានដាក់ងារអីអោយទៀត?

ខ៖ មានតែឈ្មោះជួបសម័យហ្នឹងមួយទេ!!តាំងពីតូចមកឈ្មោះតែម៉ែម៉ែហ្នឹងមករហូត។

ក៖ ហ្នឹងហើយមីងម៉ែ។ មីងសំរាប់សព្វថ្ងៃមីងអាយុប៉ុន្មានឆ្នាំហើយ?

ខ៖ ៥៣។

ក៖ ៥៣ឆ្នាំ!!

ខ៖ ហ្នឹងហើយ។

ក៖ នៅក្នុងឆ្នាំ២០១៨ហ្នឹង។ អ្នកមីងចាំខ្លួនឯងថាកើតនៅក្នុងថ្ងៃខែឆ្នាំណាដែរ?

ខ៖ កើតនៅក្នុងខែមាឃធំ។

ក៖ ចា!!ខែមាឃធំ!!

ខ៖ ហ្នឹងហើយ។

ក៖ ខែមាឃបើសិនឆ្នាំខ្មែរហេ?

ខ៖ ហ្នឹងហើយ។

ក៖ បើសិនជាឆ្នាំបារាំងមីងមើលនៅក្នុងសំបុត្រកំណើតមើល!!មីងអានដាច់ថាហី?

ខ៖ អត់ស្រួលទេ!!

ក៖ ឥឡូវញ៉ុមអានជំនួសមីងម៉ងទៅអ៊ីចឹង!! អូខេ
អ៊ីចឹងថ្ងៃខែឆ្នាំកំណើតរបស់អ្នកមីងគឺនៅក្នុងថ្ងៃទី០៦ ខែឧសភា
ឆ្នាំ១៩៦៥។ទីកន្លែងកំនើតរបស់អ្នកមីងគឺនៅក្នុងភូមិទឹកវិល ឃុំតាខ្មៅ ស្រុកកណ្ដាលស្ទឹង
ខេត្តកណ្ដាល ប្រទេសកម្ពុជា។ ទឹកវិលហ្នឹងនៅណាវិញមីង?

(ក្ងន)៖ ហ្នឹង!!

ខ៖ ទឹកវល់។

ក៖ ទឹកវល់?

ខ៖ ហ្នឹងហើយ។

ក៖ ហ្នឹងគេហៅទឹកវល់!

ខ៖ ទឹកវិលក្រោម ទៅជិតកន្លែងកោះគរ ហ្ហ!!

ក៖ ចា!!ហា!!អ៊ីចឹងកន្លែងហ្នឹងពេលមុនមិនមែនស្រុកស្អាងទេអ៊ីចឹង?

ខ៖ ស្រុកស្អាង តែយើងទឹកវល់យើងពីសង្គមមកម៉ងហា!!តាំងពីជំនាន់ដើមមកទឹកវល់!!

ក៖ ចា!!

ខ៖ ដល់យូរៗឡើងគេសរុបមកស្វាយរលំ ខេត្តកណ្ដាលហ្នឹងនេះ
សរុបចូលគ្នាមកអញ្ចឹងទៅណាស់!!

ក៖ តែគ្រាន់តែអញ្ចេកមីងពេលមុនមកដោយសារពីមុនពេលលដែលមីងកើតហ្នឹង
ពេលមុនគេហៅស្រុកកណ្ដាលស្ទឹងនៅហ្នឹង?

ខ៖ ហ្នឹង កណ្ដាលស្ទឹង ។

ក៖ តែឥឡូវដូរមកស្អាងវិញ?

ខ៖ ស្អាង។

ក៖
ហ៊ី!!អញ្ចឹងពេលមុនស្រុកកណ្តាលស្ទឹងមិនមែនទូចណាបងណោះ(និយាយទៅកាន់កូនគាត់)
មីង!!!

ខ៖ ធំណាស់។

ក៖ ចា!ដល់ពេលឥឡូវគេកាត់ ។

ខ៖
ដល់ពេលឥឡូវគេកាត់ទៅអញ្ចេះទៅ។ណាយើងណោះត្រូវនៅស្វាយរលំទេណាស់ឥឡូវគេកាត់ទៅតាខ្មៅទៀត!!

ក៖ ឥឡូវដូរហើយអញ្ចឹង?

ខ៖ ដឹងដូរទៅជាស្ពឺៗទេ។

ក៖ ចំឥឡូវដូររវល់ច្រើនម្ល៉េះ!!តែនៅនេះស្រុកស្អាងឬក៏ក្រុងតាខ្មៅ?

ខ៖ ស្រុកស្អាង។

ក៖ស្រុកស្អាងទេអ៊ីចឹងហា?

ខ៖ ស្រុកស្អាងមិនមែនតាខ្មៅទេ!!

ក៖ ពីមុនទេអានេះហ្ន៎អើរសំរាប់មីង។អ៊ីចឹងអ្នកមីងសំរាប់ឆ្នាំខ្មែរអ្នកមីងកើតសត្វអីគេវិញ?

ខ៖ ឆ្នាំរោង ឆ្នាំម្សាញ់។

ក៖ រោងហីក៏ម្សាញ់ឥឡូវ?

ខ៖ ម្សាញ់។

ក៖ ឆ្នាំរោងឆ្នាំម្សាញ់មិនដឹងមួយណា!!

ខ៖ មិនដឹងមួយណា ហ្ន៎ងហើយ!!

ក៖ អូខេអ៊ីចឹងឆ្នាំម្សាញ់អ្នកមីងពិតប្រាកដ។អ្នកមីងមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខ៖ មាន២នាក់បងប្អូន ស្រីទាំង២។

ក៖ ចឹបានម៉ែឪយកកូនតិចម្ល៉េះ?

ខ៖ ហេស៊ីសងលើគាត់តើ!!

ក៖ អញ្ចេកញ៉ុមឆ្ងល់អញ្ចេកភាគច្រើនចាស់ៗជំនាន់ដើមយកកូនច្រើនណាស់
ដល់ពេលមីងយកតែ២នាក់អ៊ីចឹងម៉ែឪ។

ខ៖ ចុះបើគាត់យកតែ២ហ្នឹង។

ក៖ ចា!! មិនមែនស្លាប់អីទៀតអីណាហ៊ី?

ខ៖ អត់មានទេ មានតែ២នាក់បងប្អូន។

ក៖ តែ២នាក់ហ្នឹងទេហេ??ស្រីទាំង២?

ខ៖ ស្រីទាំង២។

ក៖ មីងកូនពៅហ៊ីក៏កូនបង?

ខ៖ ញ៉ុមកូនបង បងគេ១០ឆ្នាំ ។

ក៖ចំ!!

ខ៖ បានមានប្អូនមួយទៀត។

ក៖ ម៉េចអ៊ីចឹងណោះមកពីគ់ាតអត់កាកកបរឿងកូនឬក៏ម៉េចណោះ?

ខ៖ ដល់ហើយទឹមតែជំនាន់អាពតនេះតើ!!ជំនាន់អាពតប្អូនញ៉ុមកើតចំឆ្នាំ៧៥(១៩៧៥)។

ក៖ អ៊ីក៏កើតចំឆ្នាំចង្រៃម្ល៉េះ។

ខ៖ សប្បាយណាស់ឆ្នាំហ្នឹង(គាត់និយាយលេង) គ្រាន់តែកើតមកមិនដឹងឆ្មបនៅឯណាទេ!!
អាយើងមាឧរាងល្អិតផងនោះ ទៅហៅយាយមប

រត់ឆ្លាឆ្លនដឹកដៃម្តាយមកផ្ទះទៀតគេយកឪពុកទៅវ៉ៃចោលហ្ន៎!!
ដល់ពេលគេយកឪពុកទៅវ៉ៃចោលនៅតែ២នាក់ម៉ែដល់ហើយម៉ែឈឺពោះទៅហៅយាយមប
ទំរាំមកដល់ពីយាយមបវិញមកដល់កន្លែងឆ្លងទន្លេណោះ ហើយ!!ផ្ទះប៉ុនខ្ទមចាក!!

ក៖ ហើយពេលហ្នឹងចូលអាពតនៅ ?ចូលហើយហើយមែនទេ?

ខ៖ ៧៥(១៩៧៥)មិនចូលអាពតពេញហើយ។

ក៖ ចា៎ ដោយសារពេលហ្នឹងជាឆ្នាំដំបូងដែលគេចូលមក
!!គេចូលមកខែប៉ុន្មានមីងដឹងទេជំនាន់អាពតហ្នឹង?

ខ៖ ៧៥(១៩៧៥) មិនដឹងខែអីទេ! មេសាអី!!

ក៖ ហ្ន៎ហ្នឹងហើយ!!

ខ៖ ៧មេសាអី?

ក៖ ហ្នឹងហើយថ្ងៃ០៧ខែមេសា។

ខ៖ ខែមេសា។ក៖ចា៎!!ខ៖ ញ៉ុមកាលគេវ៉ៃនៅភ្នំពេញនេះ ញ៉ុមគេជំលៀសទៅសំប៉ាន
បកពីសំប៉ាន់មកវិញបានចូលឆ្នាំ៧៥(១៩៧៥)។

ក៖ សំប៉ាន់កោះធំហ្នឹងហេ?

ខ៖ ចា៎ ហ្នឹងហើយ ដល់ហើយមកដល់នេះវិញម៉ែឆ្លងទន្លេគេយកឪពុកទៅវ៉ៃចោល។

ក៖ អូយ!!! អ៊ិចឹងចាំសួររឿងអាពតពេលក្រោយ ឥឡូវពីប្អូនសិន។
ហើយប្អូនអ្នកមីងគាត់ឈ្មោះអីគេ?

ខ៖ ឈ្មោះម៉ាច!!

ក៖ ជួប សាម៉ាចអ៊ិចឹងទៅ?

ខ៖ ហ្នឹងហើយ។

ក៖ ឥឡូវគាត់នៅរស់ឬក៏ស្លាប់ហើយ?

ខ៖ នៅតើ!!

ក៖ គាត់នៅនេះឬក៏នៅណាដែរ?

ខ៖ នៅនេះ!!!

ក៖ នៅខាងក្រោយនេះហេ??

ខ៖ ចា!!ផ្ទះគេនៅទីនោះឥឡូវគេជិតការកូនហើយ។

ក៖ ម៉េចដែរទំនាក់ទំនងជាមួយបងប្អូនល្អតើហី?

ខ៖ មានអី!!

ក៖ចា!!

ខ៖ ញ៉ុមមួយអាទិត្យអីមិនដែលទៅផ្ទះគេម្តងផង គេមួយអាទិត្យពីរអាទិត្យគេមកអើត
គេយកម្ហូបយកអីមកអោយយើងហូបអីអ៊ីចឹងទៅ។

ក៖ ចា!!

ខ៖ គេបាន យើងបានត្រីល្អិតអីអញ្ចឹងទៅអាណោះអត់អញ្ចឹងរត់មកយកអ៊ីចឹងទៅ
ដល់ពេលយើងអត់អ៊ីចឹងគេយកមកអោយវិញទៅ ទៅមកទៅមកបងប្អូន !!
អត់អីទេ!!អត់ដែលឈ្លោះ!!

ក៖ ហ្នឹងហើយ អ៊ីចឹងហើយល្អមីង
ដោយសារត្រូវតែរក្សាទំនាក់ទំនងមួយហ្នឹងអោយបានល្អរហូត!!ចា!!

ខ៖ ប្អូនថ្លៃញ៉ុមក៏អញ្ចឹងដែរមានប្រកាន់អីទេ។

ក៖ សុទ្ធតែអ្នកចិត្តបានមីងណោះ?

ខ៖ អត់អី។

ក៖ ហ៊ីល្អណាស់អ៊ីចឹង!!

ខ៖ អត់អឺចឹងទៅ ប្អូនយើងទៅខ្ចីមក១០០អឺចឹងទៅយើងអត់យើងទៅខ្ចី។

ក៖ តែខ្ចីហើយសងអឺចឹងទៅស្រូល រកគ្នា !!

ខ៖ តាមដំនើរអឺចឹងទៅ!! ជំពាក់គេប៉ុន្មានសងប៉ុណ្ណឹងទៅ។

ក៖ ហ្នឹងហើយអឺចឹងល្អ អឺចឹងថ្ងៃក្រោយស្រូលខ្ចីទៀត!!

ខ៖ ហ្នឹងហើយគេអោយខ្ចីទៀត។

ក៖ ហ្នឹងហើយអិចឹងមីងសំរាប់អនុស្សាវរីយ៍ដែលអ្នកមីងធ្លាបមានជាមួយប្អូនស្រីអ្នកមីងហ៉ា ពីក្មេងមកធ្លាប់លេងអីគេខ្លះជាមួយប្អូនអ្នកមីងហ៉ា លេងជាមួយគ្នាហ៉ា??

ខ៖ ហ្ហ៉កាលពីជំនាន់អាប៉ុល ពតហេ?

ក៖ ចា៉!!

ខ៖មានតែមើលប្អូនម៉ែគេយកទៅស្ទូងស្រូវអឺចឹងទៅប្អូនយើងពរទាល់តែម៉ែចេញមកពីធ្វើការវិញ បានយើងហ្នឹងយកទៅអោយម៉ែបៅអឺចឹង ម៉ោង៨
ម៉ោង៩អិចឹងអីគាត់ឡើងមកពីស្ទូងអីអញ្ចឹងហ៉ា!!

ក៖ចា៉គេអត់ថាអីអោយដែរតើហី?

ខ៖ ហ៊ី!!ថាអីអោយគាត់ធ្វើអញ្ចឹងទៅហើយ
យើងនៅកន្លែងភូមិអីនេះណោះនោះ!!!គាត់មកធ្វើក្រោយនេះដល់ហើយយើងមកនៅភូមិអ
ញ្ចេះយកប្អូនហ្នឹង អើរគាត់ឡើងទៅយើងយកប្អូនទៅអោយបៅទៅ!!

ក៖ ចា៉ហើយមីងមីងរស់នៅអើរទឹកហ្នឹងម៉ងទឹកដីផ្ទះហ្នឹងយូរនៅ?

ខ៖ តាំងពីកើតតាំងពីសង្គម ព្រោះជំនាន់រស់នៅហ្នឹងតាំងពីជំនាន់ប៉ុល ពត។

ក៖ អញ្ចឹងដីមីងហ្នឹងរាល់ថ្ងៃហ្នឹងដីកេរ្តឹ៍ទេអញ្ចឹង?

ខ៖ មិនមែនដីកេរ្តឹ៍ទេ ដីទិញគេ !!

ក៖ ទីញគេប៉ុន្តែ!!

ខ៖ ទិញគេនៅថ្នល់ហ្ន៎!!!លក់បាត់ហើយ!!គេដកយកធ្វើបន្ទាយធ្វើអីហ្នឹង។

ក៖ ហ្ន៎កន្លែងបន្ទាយហ្នឹងហី?

ខ៖ ហ្នឹងហើយកន្លែងបន្ទាយហ្នឹង។

ក៖ ហ្ន៎ស្គាល់ហើយជិះមកមិញកាត់ដែរ!!

ខ៖ បន្ទាយហ្នឹងក៏គេដកយកដែរ ដកយកអស់ហាហ្នឹង!!មានដីណា!!

(ក្ងន)៖ ដីខាងនេះក៏គេដកដីខាងនោះក៏គេដក។

ខ៖ គេយកមកចែកក្ងនទាហានគេលក់ហ្អែង!!

ក៖ តែយើងលក់អោយគេតើហី?

ខ៖ អត់ទេ អត់ទេ គេត្រូវដកយក
ហើយយើងនេះក៏ត្រូវចេញមកទិញនេះទៅ!!យើងមុនដំបូងគេដកយក គេដកយកហើយ
យើងទៅនៅល្វាឯម ដល់ទៅនៅល្វាឯម
លក់ដីល្វាឯមមកនៅនេះវិញមកនៅនេះយើងមកទិញដីនៅនេះអញ្ចឹងទៅ។

ក៖ ហ្ន៎ហើយដីមីងនៅនេះទំហំប៉ុន្មានដែរ។

ក៖ ៧ម៉ែត្រ បណ្តោយប៉ុន្មាន៤០ម៉ែត្រលក់អស់ប៉ុន្មានម៉ែត្រហើយ
រវល់តែកូលឈឺម្តាយឈឺហ្នឹង។ក៖ចា!!ខ៖ នៅសល់ប៉ុន្មាន១៧ម៉ែត្រអី។

ក៖ តែគ្រាន់តែបានធ្វើផ្ទះធ្វើអីនៅស្រួលអីដែរ!!

ខ៖ ប៉ុន្មានទេ!! គ្រាន់តែដោះស្រាយការឈឺចាប់។

ក៖ ចា៎ហើយមីងមានចាំអីគេខ្លះទៀតពីម្ហូនទេ
ចំនុចកន្លែងណាដែលមីងស្រលាញ់ម្ហូនជាងគេអញ្ចឹងហា!!

ក៖ កាលពីក្មេងអើរបើអស់ពីឪពុកទៅយើងមិនថែទាំម្ហូន
គ្រាន់តែគេវ៉ៃបន្ដិចបន្ដួចអើយខ្លាចតែគេធ្វើបាបម្ហូន ជំនាន់អាពតហា!អៀវកាត់ព្រៃកាត់ផ្សែង

ទូលអាស្លឹកធាងខេត្រហ្នឹង ដឹកដៃប្អូនបណ្តើរ
យកស្លឹកទូលអាធាងខេត្តមកដល់កន្លែងដើមចាយហ្នឹង!!

ក៖ចា៎!!

ខ៖
ខ្លាចគេធ្វើបាបប្អូនហ្ន៎!!ចុះបើដាក់នៅការដ្ឋានចុះបើគេរវល់គិតគូរតែកូនគេគេមិនមែនគិតគូរអីប្អូនយើងទេហើយម៉ែទៅតែស្ងួងដក !!

ក៖ចា៎!!ពេលគាត់រៀងត្រើសមកមីងចូលចិត្តលេងអីគេជាមួយគាត់ជាងគេ?

ខ៖ ញ៉ុមចូលចិត្តតែលេងឆ្កឹះកៅស៊ូ!!បាញ់ទ្រុយ ទាត់បាល់។

ក៖ ស្ពឺគេបាញ់ទ្រុយហ្នឹង?

ខ៖ ហ៊ីអាបាញ់!!

ក៖ អាបាញ់ត្រង់ហ្នឹងមែន?

ខ៖ មូលប៉ុននេះជ័រហ្ន៎!!ដាក់ហ្អេងបាញ់!! ប្អូននៅអង្គុយចាំរើស!!បោះឃ្លីអ៊ីចឹងដែរ!!

ក៖ បោះឃ្លីដែរ ដល់គេរាងធំបន្តិច ដល់ហើយគេធំទៅយើងរាងប្រលែងដៃគេទៅកាប់អំពៅ ដល់ទៅកាប់អំពៅអ៊ីចឹងទៅម៉ែហើយប្អូននៅផ្ទះអ៊ីចឹង មួយថ្ងៃ៥០។

ក៖ហ៊ីៗ!!

ខ៖ ហេ២ថ្ងៃ៥០។

ក៖ចា៎!!

ខ៖ យកមកបានអង្ករទិញអង្ករខ្លះម្ហូបខ្លះទៅ
ហ៊ីដល់ហើយយើងទៅនៅភ្នំពេញទៅដល់ហើយយើងបានប្រាក់ខែយកមកអោយម្តាយ។

ក៖ចា៎!!អញ្ចឹងគិតទៅជាមួយប្អូនមីងមើលប្អូនបានច្រើនដែរអញ្ចឹងហា៎ ថែទាំគាត់ហា៎!!

ខ៖ ហេ!! ដល់ហើយបានលុយមកអញ្ចឹងទៅណាស់
ដល់ហើយគេអោយចាយយើងអត់ហ៊ានចាយទេណាស់សុខចិត្តយកមកដាក់ក្នុងជើងសំពត់
យកមកប្រាប់ថាម៉ែលុយនៅក្នុងជើងសំពត់ហ្ន៎!!ម៉ែងងយកទៅទិញអង្ករទិញអីទៅ
យកទៅទំរាំបានមួយខែទៀតគាត់អោយលុយខ្លះមកយកលាក់ខ្លួនឯងហ្នឹងខ្លះទៅហើយអង្ករប៉ុ
ន្មានខែអ៊ីចឹងគាត់អោយប៉ុន្មានតៅ!!

ក៖ អាហ្នឹងពេលបែកប៉ុលពតហើយឬក៏មុន?

ខ៖ បែកប៉ុល ពតហើយ៩៣(១៩៩៣)។

ក៖ចា៎!! ឥឡូវអស់ពីប្អូនហើយចូលដល់ម្តាយម្តង។អ្នកមីងម្តាយឈ្មោះអីគេវិញ?

ខ៖ ឈ្មោះនុត មន!!

ក៖ មីងចាំថ្ងៃខែឆ្នាំកំណើតគាត់ទេ?

ខ៖ អត់ចាំទេ។

ក៖ ឥឡូវមើលនៅក្នុងសំបុត្រ!!ម្តាយអ្នកមីងឈ្មោះនុត មន សញ្ជាតិខ្មែរកើតនៅថ្ងៃទី០៤
ខែមិថុនា ឆ្នាំ១៩៤៦។ចា៎ហ្នឹងហើយ
អ៊ីចឹងគាត់កើតនៅទីកន្លែងកំនើតរបស់គាត់នៅដូចមីងដែរគឺនៅក្នុងភូមិទឹកវល់
!!ហ្នឹងហើយណោះមីងណោះ?

ខ៖ ហ្នឹងហើយ។

ក៖ ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ប្រទេសកម្ពុជា
!!មួយហ្នឹងឥឡូវគេដូរអស់ហើយ!!

ខ៖ ដូរអស់ហើយ!!

ក៖ ហ្នឹងហើយ មីងចាំម្តាយមីងគាត់កើតឆ្នាំខ្មែរគាត់កើតសត្វអីគេទេ?

ខ៖ ម៉ែញ៉ុមកើតសត្វពស់ដូចញ៉ុមដែរ!!ឆ្នាំម្សាញ់!!

ក៖ ហ្ន៎ម្សាញ់ដូចគ្នាដែរ!!ឆ្នាំម៉ែឆ្នាំកូនគឺតែមួយ?

ខ៖ តែមួយ។

ក៖ ចា៎!! មីងម្តាយរបស់មីងដើម្បីរកស៊ីចិញ្ចឹមមីងគាត់ធ្វើការងារអីគេខ្លះតាមតែមីងដឹងមកហា៎?

ខ៖ តាមដឹងក្តីមកយើញតែម៉ែញ៉ុមធ្វើដេញរោងតាំងហ៊ុន រោងតាំងហ៊ុន។

ក៖ តាំងហ៊ុនហ្នឹងមីសូរយើងហ្នឹងមែន?

ខ៖ មីសូរយើងហ្នឹងគេហៅតាំងហ៊ុន!!

(ក្ងន)៖ ឥឡូវកន្លែងហ្នឹងគេហៅស្ពានទឹកវល់ផង ព្រែកតាំងហ៊ុនផង។

ក៖ហ្ន៎សំបូរគេធ្វើអាហ្នឹងមីងណោះ?

ខ៖ ហ្នឹងហើយ រោងចក្រគេធំណាស់ ថាឡើងហាលលើដំបូលលើអីអញ្ចឹងទៅ!!

ក៖ អាហ្នឹងពេលជំនាន់មុនមីងណោះ?

ខ៖ ជំនាន់ណោះ!!

ក៖ លន់ នល់!!

ខ៖ ហ្នឹងហើយ។

ក៖ ចុះអាមុនលន់ នល់ហ្នឹងទៀត?

ខ៖ អត់ទាន់ទេ អត់ទាន់ដឹងខ្យល់ទេ!!

ក៖ហ្ន៎ហ្នឹងហើយ មីងកើត៦៥(១៩៦៥)ណោះហើយ អ៊ីចឹង!!

ខ៖ ហេ៦៥(១៩៦៥)។

ក៖ ហ្នឹងហើយ៦៥(១៩៦៥)ដល់ពេលអា៥ឆ្នាំហ្នឹងមីងអត់ទាន់ដឹងអីច្រើនទេ!!

ខ៖ អត់ដឹងខ្យល់។

ក៖ ដល់ពេលចូលដល់អាសង្គ្រាមនេះ!!

ខ៖ ហ៊ីអាហ្នឹងបានដឹងច្បាស់ម៉ង!!ដឹងច្បាស់ការដឹងរឿងការជូរចត់ហ្នឹងម៉ង!!

ក៖ ចា៎!!អ៊ីចឹងអ្នកមីងក្រៅពីការធ្វើតាំងហ៊ុន
មីសូរហ្នឹងមកម្តាយរបស់អ្នកមីងគាត់មានធ្វើអីគេផ្សេងទៀតទេ?

ខ៖ អត់ទេ?

ក៖ ចុះស្រែចំការ។

ខ៖ ជំលៀសទៅសំប៉ាន់!!ហ្ហ៉ម៉ែញ៉ុមអត់ទេធ្វើតែអាហ្នឹង!!

ក៖ តែអាហ្នឹងតែមួយមុខទេដាំបន្លែអីរ៉ាន់ក៏អត់ដែរ?

ខ៖ អត់ទេ!!តាញ៉ុមគាត់ដាំ!!

ក៖ចា៎!!

ខ៖យាយញ៉ុមគាត់ដាំ។

ក៖ អញ្ចឹងអ្នកមីងសំរាប់ម្តាយរបស់អ្នកមីង
គឺគាត់មានជាមនុស្សដែរយ៉ាងម៉េចដែរអ្នកមីង?រៀបរាប់ចរិកស្រិនរបស់ម្តាយរបស់អ្នកមីងមើ
ល?

ខ៖
ម្តាយញ៉ុមហេ!!ម៉ែញ៉ុមចរិករបស់គាត់សុភាពទោះបីសូម្បីតែអង្គុយក៏ដោយហ៉ា!!គេសូរមួយម៉ា
ត់ឆ្លើយមួយម៉ាត់ដូចប្អូនញ៉ុមអញ្ចឹងមិនដូចញ៉ុមទេ។ក៖ចា៎!!ខ៖ បើគេសូរអ៊ីចឹងទៅឆ្លើយទៅ
គេដើរ សូម្បីតែគេដើរមុខផ្ទះក៏ដោយ អត់សូរក្មេងទៅណា!! មានតែគេយាយអើរអង្គុយធ្វើអីគេ
អង្គុយមើលចៅមើលអីអញ្ចឹងទៅ។បើថាហើយរួចអត់ដែលទៅអង្គុយផ្ទះគេទេ
ថានៅណានៅហ្នឹងហើយ បើអោយម៉ែចាំផ្ទះម៉ែចាំតែផ្ទះហ្នឹង មើលចៅមើលអីគាត់អញ្ចឹងទៅ!!
ដាំបាយដាំអីអោយចៅអ៊ីចឹងទៅ
ស៊ីហើយអីហើយអោយមុជទឹកមុជអីគាត់លួងអោយដេកហើយ
តែមីនេះបៅតែដោះស្វីតគាត់ហ្នឹង!! ញ៉ុមទៅហើយទៅរកត្រីរកអីរហូត
មិនដែលម៉ែញ៉ុមណាមានរឿងជាមួយញាតិជិតខាងអីណាសោះ!!

ក៖ចា៎!!

ខ៖ អត់កមានថាហេអ្នកនេះមកសួរថាអញ្ចេះអ្នកនេះមកសួរថារឿងអញ្ចេះអញ្ចុះថារឿង
អត់ទេ!! ហើយញ៉ុមក៏អញ្ចឹងដែរ មិនដែលមានញាតិជិតខាងណាមកថាអញ្ចេកអញ្ចុះទេ!!

ក៖ចា៎មីងសុភាពសឹងអីហើយ!!

ខ៖ សូម្បីតែផ្ទះគេជុំវិញហ្នឹង ផ្ទះគេអត់មានសត្រូវទេ!!

ក៖ចា៎!!

ខ៖ មានតែគេមានអីយកមកអោយយើងហ្ងប។

ក៖ ចា៎ល្អហើយអ៊ីចឹងណាស់មីណាស់!!
ហើយចុះម្តាយចំនុចកន្លែងណាដែលអ្នកមីងស្រលាញ់គាត់ខ្លាំងជាងគេ?

ខ៖ ញ៉ុមស្រលាញ់គាត់កាលពេលជំនាន់ប៉ុល ពតគាត់ចេះតែយើង
អត់អោយយើងរបូតពីដៃគាត់ហា៎!!!

ក៖ចា៎!!

ខ៖ បើគេខ្លះគេរុញចោលហើយ
គេសុខចិត្តរកតែព្រះអាយូសទេ!!ទៅដល់ណាក៏គាត់យកទៅដែរ
មកវិញក៏គាត់យកមកវិញដែរមកអត់ឃ្លានមានស៊ីអ៊ីពីរនាក់ម្តាយហើយនឹងប្អូនហ្នឹង។

ក៖ អញ្ចឹងចំនុចហ្នឹងមីងណោះ
ស្រលាញ់ថ្នាក់ថ្នមថែទាំមីង។ចា៎!!មីងមានចាំអីគេទៀតពីម៉ែទេ?អត់មានទេហេអស់ហើយហេ?

ខ៖ មានតែដល់ពេលនឹកយើញដល់ពេលគាត់ស្លាប់ទៅញ៉ុមអានិតម្តាយដែរ។

ក៖ហ៊ឺ!!

ខ៖ យើងក្រអត់មានអីធ្វើបុណ្យអោយគាត់ ធ្វើបុណ្យអីហ្នឹង។

ក៖ ចា៎!! ឥឡូវមីងចូលដល់ឪពុកវិញម្តងមីងឪពុកឈ្មោះអីគេវិញ?

ខ៖ ឈ្មោះ ជួប ជុំ។

ក៖ ជួប ជុំ!!

ខ៖ ញ៉ុមត្រកូលតាហ្នឹង!!

ក៖ ហ្នឹងហើយ អ៊ីចឹងថ្ងៃខែឆ្នាំកំនើតរបស់ឪពុករបស់អ្នកមីងគាត់ឈ្មោះជួប ជុំកើតនៅក្នុងថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៤៥ នៅភូមិទឹកវល់ ឃុំ តាខ្មៅ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលប្រទេសកម្ពុជាដែរ!!អ៊ីចឹងឪពុកម្តាយអ្នកស្រុកតែជាមួយគ្នាហ្នឹងមីងណោះ?

ខ៖ ស្រុកជាមួយគ្នាបងប្អូនជីដូនមួយ។

ក៖ អ៊ីយ៉ាស់!! ដូចម៉ែឪញ៉ុមដែរហ្នឹងអ៊ីចឹង!!

ខ៖ បងប្អូនជីដូនមួយ!!

ក៖ ចា!! មីងឪពុករបស់អ្នកមីងគាត់កើតឆ្នាំសត្វអ៊ីគេវិញ?

ខ៖ ថោះ!!

ក៖ ថោះហា!!ទន្សាយ!!

ខ៖ទន្សាយថោះ។

ក៖ អូ!!មិញងាកក្រោយបន្តិចសិន ម្តាយអ្នកមីងគាត់ស្លាប់មូលហេតុអ៊ីគេដែរ?

ខ៖ ម៉ែស្លាប់ដោយសារជំងឺចាស់ ហើយគាត់ដួលទៅ
ហើយដល់អញ្ចឹងទៅយើងអត់មានលុយកាក់អ៊ីអញ្ចឹងទៅចេះអញ្ចឹង ហៅគាត់ទៅពេទ្យ គាត់ថាអត់ទៅទេ!!ម៉ែអត់ទៅទេ តែមុនគាត់រៀបនឹងស្លាប់ហ្នឹងហ៊ា!!តែបាយគាត់ក៏អត់ហូបដែរ ហើយគាត់ថាធំឆ្អាបទាំងអស់ហើយអត់អោយគាត់ហូបទេ ម៉ែកុំទៅម៉ែនៅថែទាំកូន។

ក៖ ផ្តាំចុងក្រោយអ៊ីចឹងទៅ?

ខ៖ ហើយអត់មានអោយយើងពិបាកអី ឃើញគាត់ចោកខ្លួន ដកដង្ហើមអ៊ីអោយពព្រ៊ីពព្រុស !!ញ៉ុមឃើញគេអ្នកខ្លះហ៊ាត្រដរខ្សល់ផុតអញ្ចឹងគាត់កំពុងតែសំរានអញ្ចឹង ញ៉ុមហាលលៀស

អ៊ីចឹងគាត់ប្រាប់យើងអញ្ចឹង!!ម៉ែហ៊ាអាចមន៍គោនៅផ្លូវហ្នឹងកូនឯងកើបយកទៅក្រវត្តចោលទៅ
កុំអោយមានគេអី គេខ្ជើមអីកូន។ញ៉ុមណោះចាំតិចទៀតម៉ែ
ចាំអិនទៅលក់លៀសទុកម៉ែនៅហ្នឹងទៅទុកជាមួយប្តីហ្នឹងទៅ មានស្អី
ទៅអង្គុយៗគាត់ថាហ៊ីលើកអញដាក់លើគ្រែ គេនោះក៏លើកដាក់លើគ្រែ
លើកដាក់លើគ្រែហើយ គាត់សំរានអ៊ីចឹងហើយគាត់ថាហ៊ីក្តៅណាស់
ក្តៅ!!ហើយញ៉ុមសួរថាដាក់ទឹកកកហ៊ីម៉ែ? ហ៊ីដាក់បន្តិចមកកូន
ហ៊ីដាក់ទៅហើយក៏ជូនខ្លួនអ៊ីស្អាត ហ៊ីដាក់អោយអញដេកអោយស្រួលមក
ដេកទៅហើយអង្គុយពិភាក្សាជាមួយយើង យកចានដេកដាក់លៀសយកលក់ទៅ មានណា
មើលទៅម៉ែប្រឈរភ្នែកស្រឹម !!ថាពព្រ៊ីសពព្រុសអ៊ីតឹងអ៊ីឮអ៊ីអត់ទេ ទៅស្រឹម
ហើយរត់ទៅហៅបង បងហ៊ាបងបងឯងទៅមើលម៉ែ
បងឯងជួយមើលមើលម៉ែម៉េច!!ហ្នឹង!!ហ៊ីគាត់តែប៉ុណ្ណឹងហើយអើយ!!ញ៉ុមថាហៅម៉ែដូចប្រឈរ
ភ្នែកបង!!ថាហ៊ីគ្មានទេ!!អញឃើញគាត់សំរានតែប៉ុណ្ណឹង!!ហើយម៉ែប្រឈរភ្នែកសឹមអ៊ីចឹងតិចៗ
ម្តងតិចម្តង តិចថយៗៗទៅ។

ក៖ អត់មានពិបាកអ៊ីសោះម៉ង?

ខ៖ អត់មានពិបាកអ៊ីសោះ អត់ដូចគេ ញ៉ុមឃើញគេពព្រ៊ីពព្រុសឆ្លាឆ្លន់អ៊ីអត់!!

ក៖ នេះគាត់ទុំទៅម៉ងមីងណោះ?

ខ៖ ចា៎ហ្នឹងហើយ។

ក៖ ចា៎ហ្នឹងហើយអ៊ីចឹងឪពុកមិញវិញ ឪពុកអ្នកមីងគាត់អ្នករកស៊ីអ៊ីគេដែរមុនគាត់ស្លាប់ហ៊ា??

ខ៖ មុនគ៉ាតស្លាប់ធ្វើតាំងហ៊ុនដូចគ្នាអ៊ីចឹង!!

ក៖ ហ្ហ!!គាត់អត់ធ្លាប់ធ្វើអ៊ីផ្សេងទៀតទេហេ?

ខ៖ អត់ទេ។

ក៖ អ៊ីចឹងគ្រាន់តែធ្វើតែមីសួរហ្នឹង?

ខ៖ ធ្វើតែមីសូរហ្នឹង
ម៉ារោងចក្រហ្នឹងភូមិលេខ១ហ្នឹងចូលហ្អែងម៉ាចុងព្រែកអាខាងណោះអាខាងណោះហ្នឹង!!គេវ៉ៃ
គេមានដុំប៉ុននេះគេក្រឡុកអាហ្នឹងញ៉ុមយើញពីទូចទេណាស់ អាហ្នឹងអំញ៉ុមអីវ៉ាន់គាត់ក្រឡុក។

ក៖ របៀបធ្វើមីសូរហ្នឹងមីងហេ?

ខ៖ ហ្នឹងហើយ
ដល់គេក្រឡុកដូចវ៉ៃនំបញ្ចុកដល់ពេលក្រឡុកទៅអញ្ចឹងដល់ហើយគេដាក់កន្ត្រុងវាប៉ុននេះញ៉ូ
មយើញប្រុសៗដាក់អាខ្ទះប៉ុននេះទៀតដាក់អានេះធុងហ្នឹងពីលើអញ្ចឹងទៅវ៉ៃតប់ៗៗម្សៅចេះ
តែចេញចេញទៅរហូត ដល់ហើយគេប្រហូរចូលទៅឈន់ ទីវ
ដល់លើកពីឈន់ទីវហ្នឹងមកស្រីៗចុះទឹកត្រឹមៗនេះទៅបារយកមកដាក់ឬស្សីប៉ុនៗមេជើងប្រវែ
ងៗនេះដល់ហើយគេដាក់នៅស្នូលហ្នឹងវដ្តៗវាទៅកាត់យកតែម៉ាស្មើហ្នឹងអ៊ីចឹងទៅ
ដល់ហើយបានគេជញ្ជូនយកទៅដាក់ហាលអាណាឡើងលើដំបូលឡើងទៅញ៉ុមនៅអង្គយមើ
លចាស់ៗ
ដល់ល្ងាចឡើងគេមិនបំបោសអាកន្ទិចៗដីអីជាប់តិចតូចហ្នឹងមានអីញ៉ុមទៅលូចដែលគេហាល
នៅមាត់ព្រែកហ្នឹង។ក៖ចា៎!!ខ៖
ទៅចាប់ទាញអ៊ីចឹងជូនកាលគេអោយទាំងដុំទាំងដុំក៏រត់ឆ្លងព្រែកពីទូចតែអញ្ចឹងតែអត់ដឹងទៅ
ធ្វើអីទេអត់ដឹងទេ។

ក៖ ឥឡូវមីងនិយាយពីឌីមើលគាត់ជាមនុស្សដែរចរិកម៉េចដែរមីងអារៀបរាប់មើល?

ខ៖ អត់ស្គាល់
ពីព្រោះគាត់ធ្វើអីញ៉ុមអត់សូវដឹងអីញ៉ុមទៅសំប៉ាន់បែកគ្នាដល់ហើយទៅទាំងអស់។

ក៖ អ៊ីចឹងគាត់ស្លាប់ហ្នឹងមីងអាយុបាន១០ឆ្នាំមីងហេ?

ខ៖ ញ៉ុមបាន១០ឆ្នាំបានពោះធំមីអូនហ្នឹងហើយគាត់ស្លាប់។

ក៖ ហើយក៏ប្តី(ឌីពុក)ស្លាប់ទៅ?មីងនៅចាំអីគេខ្លះៗពីឌីទេ?

ខ៖ ហ៊ុ!! គាត់ដូចពីសង្គមដូចគាត់ចិត្តល្អគ់ាតអត់សូវបានថ្នាក់ថ្នមយើង
គាត់រវល់តែមកធ្វើការដល់ពេល!!

ក៖ ក្មនតែមួយគូរតែថ្នាក់ថ្នមមែនទេ?

ខ៖ ពេលយប់ជួនកាលញ៉ុមដឹងខ្លួនមាន់រងារមិនទាន់ !! ម៉ាស៊ីនគេហ្នឹងអត់ពន្លត់សោះ!លឺតែតុកតាក់តុងតាក់ធ្វើធ្វើ ដល់ពេលគាត់ត្រូវពេលថ្ងៃឈប់គាត់ត្រូវឡើងសំរានហើយ សំរានអត់មានទៅផ្ទះទេ សំរាននៅក្នុងកន្លែងធ្វើហ្នឹងម៉ង។

ក៖ អ៊ីចឹងធ្វើរហូតម៉ង?

ខ៖ គាត់មិនធ្វើរហូតទេប៉ុន្តែគាត់ផ្លាស់វេនហ៉ា !! ជួនកាលនាំញ៉ុមដើរលេងអ៊ីចឹងទៅ ហូបនំបញ្ចុកហូបអីហ្នឹង។

ក៖ បានដើរលេងដើរអីដែរហេ?

ខ៖ បានដើរលេងដើរអីដែរ។

ក៖ ហើយមានដែរធ្លាប់ឧអីវ៉ាន់ធ្លាប់យកទៅលេងផ្ទះតាយាយអីអត់?

ខ៖ អែវទៅរហូត ។

ក៖ហ្ហ៉!!

ខ៖ ពរទៅរហូតដែរ តែគ្រាន់តែថាគាត់អត់នេះទេមើលដែរ តែមើលមិនដិតដល់ដូចគេណាស់!!ប៉ុន្តែម៉ែឧគេគ្រប់គ្នាក៏អ៊ីចឹងដែរ។

ក៖ ដោយសារគាត់ត្រូវរកស៊ីដើម្បីចិញ្ចឹមគ្រួសារ។

ខ៖ រកស៊ីចិញ្ចឹមយើង។

ក៖ ឥឡូវចូលដល់យាយតាខាងម្តាយសិនយាយឈ្មោះអីគេដែរមីង?

ខ៖ ឈ្មោះយាយប៉ាត់។

ក៖ ចាំត្រកូលយាយប៉ាត់ទេ?

ខ៖ អត់ទេស្គាល់តែប្តីប្រពន្ធគាត់។

ក៖ មីងកើតទាន់គាត់ទេ?

ខ៖ អត់ទាន់ផង។

ក៖ ហើយអើរអត់ទាន់សោះម៉ងហេ?

ខ៖ អត់ទាន់។

ក៖ ពេលមីងកើតមកគាត់ស្លាប់បាត់ហើយហេ?

ខ៖ គាត់ស្លាប់បាត់ហើយ ឃើញតែយាយចុងហ្នឹង!!

ក៖ ហ្ហ៉ាយាយចុង!!

ខ៖យាយចុង!!

ក៖ តែយាយរបស់ម៉ែមីង អ្នកមីងអត់ទាន់ទេ?

ខ៖ អត់ទាន់

ក៖ ហើយចុះម៉ែមានដែរនិយាយអីប្រាប់ពីម៉ែអីអត់មីង?

ខ៖អត់!!

ក៖ អត់ដែលសោះម៉ងថាយាយម៉េចៗអ៊ីចឹង ស្លាប់មូលហេតុអី?

ខ៖ គាត់និយាយនិយាយអ៊ីចឹងពីប្រវត្តិគាត់រឿងគាត់ជីតស្លាប់។

ក៖ ម៉េចវិញមីងនិយាយមើល!!

ខ៖ ថាគាត់អើយពិបាកនៅក្នុងខ្លួនអីអ៊ីចឹងទៅណាស់គាត់ថា
អញអត់បាននៅជួយមើលបងប្អូននៅមើលថែទាំបងប្អូនបានទេ អីអ៊ីចឹងទៅណាស់
អាហ្នឹងគាត់បាននិយាយពិត!!ហើយញ៉ុមក៏អត់សូវបានសូរដេញដោលច្រើននិយាយអីបើអត់
ដែលឃើញមុខគាត់អីផង។

ក៖ចា៉!!ហើយដឹងថាយាយអ្នកនៅភូមិណាទេ?កើតនៅស្រុកណាវិញទេ?

ខ៖ នៅខាងស្អីគេ!!នៅខាងពូព្រិតហ្នឹងមិនដឹងណាស្អីទេ ស្ត៊ី ហីអីទេ!!

ក៖ កំពង់ស្ត៊ី?

ខ៖ មិនមែនទៅដល់ហ្នឹងទេយើងនេះ ទៅតាមផ្លូវព្រែកហូរនេះ ចុះតាមព្រែកហូរនេះ!!

ក៖ ព្រែករាំងហេ?

ខ៖ ហូសព្រែករាំងហ្នឹងទៅទៀត!!ស្អីទេ!!

ក៖ តែនៅក្នុងខេត្តកណ្តាលហ្នឹងដែរទេមីងហេ?

ខ៖ ខេត្តកណ្តាលទេ!!

ក៖ចា៉!!

ខ៖ យាយញ៉ុមហ្នឹងកូនចិន!!

ក៖ចា៉!!

ខ៖ដល់តាញ៉ុមកូនខ្មែរ ដល់ទៅគាត់ទៅដណ្តឹងប្រពន្ធយូរៗ !!យាយកាត់ចិន!!

(កូន)៖ម៉ាក់យាយញ៉ុមនៅក្របៅ។

ក៖ហ្ហ៉ានៅក្របៅ បើហូសព្រែករាំងក្របៅហ្នឹងហើយអ៊ីចឹងហ្ហ៉!!

ខ៖ មិនមែនទេ ស្អីទេញ៉ូមធ្លាប់ទៅលេង!!

ក៖ តាឥដ្ឋអីទេហេ!! ដីឥដ្ឋ ស្វាព្រាម។

ខ៖ រោងម៉ាស៊ីនគេទៅដល់នេះគេតាមញ៉ុមធ្លាប់ទៅដែរ។

ក៖ អត់អីទេ បើរកមិនឃើញអត់ដឹងម៉េចដែរ!!

ខ៖ អត់ដឹងដែរ។

ក៖ មានអីចង់និយាយពីយាយរបស់មីងទៀតទេ?

ខ៖ អត់ទេព្រោះអីញ៉ុមអត់ស្រវជឹងពីប្រវត្តិគាត់ អត់ដែលស្គាល់គាត់។

ក៖ ចា៎ !!ឥឡូវដល់តាខាងម៉ែវិញម្តងឪរបស់ម៉ែគាត់ឈ្មោះអីគេវិញ?

ខ៖ ឈ្មោះនុត។

ក៖តានុត?

ខ៖ ស៊ិន នុត។

ក៖ ស៊ិន នុត!!មីងកើតទាន់គាត់ទេ?

ខ៖ ទាន់។

ក៖ ទាន់តាវិញហេ?

ខ៖ ទាន់តា ។

ក៖
អ៊ីចឹងតាមេម៉ាយ!!យាយស្លាប់ចោលមុន!!អ្នកមីងសំរាប់តារបស់អ្នកមីងមីងចាំថាគាត់កើតនៅពេលណាអីអត់?

ខ៖ អត់បានដឹង។

ក៖តែតាឆ្នាំខ្មែរតាឆ្នាំអីគេវិញ?បើកើតទាន់មីងគួរតែដឹងដែរហើយ!!ឬក៏ភ្លេចគាត់?

ខ៖ សេះគាត់។

ក៖ មមីអ៊ីចឹងហេ?

ខ៖ ហ្ន៎ងហើយ!!

ក៖ ហ៊ីមីងចាំណ្ហហ៎!!

ខ៖ ហេអត់ទេដំណាលឪតា សម្តេចតា។

ក៖ ដំណាលសម្តេចតា?

ខ៖ ហ្នឹងហើយ!!

ក៖ អញ្ចឹងពេលសម្តេចតាស្លាប់២០១២ហើយគាត់៩១ អ៊ីចឹង២០១២តារបស់មីងគាត់៩១ឆ្នាំ?

ខ៖ ហ្នឹងហើយ។

ក៖ ហើយដល់ពេលបូកថែម៦ឆ្នាំទៀត បើនៅឥឡូវ៩៧
ហ្នឹងហើយបើនៅ៩៧ហើយបើនៅទាល់តែឥឡូវហ្ន៎!!មីងដឹងថាគាត់ស្លាប់ពេលណាទេ?

ខ៖ គាត់ស្លាប់ពេលជំលៀសទៅសំប៉ាន់។

ក៖ នៅក្នុងជំនាន់ប៉ុល ពតទេអ៊ីចឹងហេ?

ខ៖ ជំនាន់ប៉ុល ពត។

ក៖ ឆ្នាំប៉ុន្មានមីងចាំទេ ចូលអាពតបានប៉ុន្មានឆ្នាំបានគាត់ស្លាប់?

ខ៖ គាត់ស្លាប់៧៤(១៩៧៤)។

ក៖ ស្លាប់ចូល៧៤(១៩៧៤)ជិតចូលអាពត។

ខ៖ ចូលអាពតហើយ យើងជំលៀសទៅសំប៉ាន់គាត់ស្លាប់នៅសំប៉ាន។

ក៖ ៧៤(១៩៧៤)មានទាន់ចូលជំនាន់ប៉ុល ពតណា!!

ខ៖ ៧៤(១៩៧៤)យើងមកណេះ៧៥(១៩៧៥)។

ក៖ហ្ន៎!!

ខ៖ យើងឡើងមកវិញ៧៥(១៩៧៥)។

ក៖ចាំ!!

ខ៖ បានមានអ្នកហ្នឹង»!!

ក៖ អ៊ីចឹងតាមីងស្លាប់១៩៧៤។មីងដឹងចាំគាត់ស្លាប់អាយុប៉ុន្មានទេ?

ខ៖ អត់បានដឹងដែរនៅតូចពេក!!

ក៖ ចា!!តូចពេកហេ!!

(ក្ងន)៖ គិតទៅដកពី៧៤(១៩៧៤)មកទល់ឥឡូវ២០១៨។

ក៖ ហ្នឹងហើយអ្នកណាគេចង់ដឹងអោយគេដកទៅ
អ្នកណាគេអ្នកស្គាប់ចង់ស្រាវជ្រាវប្រវត្តិអ៊ីវ៉ាន់ទៅដឹងហើយ។

ខ៖ ស្រាវជ្រាវឆ្នាំ។

ក៖
យើងនិយាយតែឆ្នាំគាត់ស្លាប់យើងនិយាយតែឆ្នាំយើងដឹងយើងដឹងអ៊ីចឹងទៅតែគេរកហ្ន៎អាហ្នឹងគេយើញម៉ង!! គាត់អ្នកស្រុកណាវិញលោកតា?

ខ៖ គាត់នៅស្វាយរលំនៅម៉ាត្រកូលគាត់ហ្នឹង!!

ក៖ នៅកន្លែងហ្នឹងដែរហេ?

ខ៖ នៅហ្នឹងដែរ។

ក៖ នៅទឹកវល់?

ខ៖ នៅទឹកវល់។

ក៖ ឃុំតាខ្មៅ ស្រុកកណ្តាលស្ទឹង
ខេត្តកណ្តាលហ្នឹង!!មីងចាំអីគេខ្លះពីតា?ពេលអនុស្សាវរីយ៍ពេលដែលមីងលេងជាមួយតាតើតាម៉េចដែរ?

ខ៖
ហ៊ីគាត់កាលញ៉ុមនៅពីក្មេងគាត់ឃើញឪពុកខ្ញុំមិនសូវថ្នាក់ថ្នមអ៊ីចឹងគាត់យកញ៉ុមមកដើរតាមបុណ្យដើរតាមអ៊ីរហ្ងតហ្នឹង។

ក៖ ចា!!មកមើលគោមើលអីជាមួយគាត់?

ក៖ថ៎!!

ខ៖ ដាំពោតដាំអី!!ដល់ពេលជំលៀសទៅសំប៉ាន់តាញ៉ុមទៅស្លាប់នៅលើអង្រឹងតើ!!!!

ក៖ហ៊ី!!

ខ៖ គាត់ឈ្លោះប្តីប្រពន្ធគាត់ទៅប្រពន្ធគាត់អត់សូវមើល ដល់គាត់ដូចតែម៉ែញ៉ុមអញ្ចឹង
ម៉ែញ៉ុមស្លាប់នៅលើគ្រែអត់មានត្រដរខ្យល់ ដល់ពេលគាត់ស្លាប់ញ៉ុមអត់ដឹងដែរ
ដឹងតែលឺគេយំមើលគេទៅ!!តែអាណាទៅស៊ីបបរតាអញអត់បានទេរ៉ើយ!!ប្រាប់គេអញ្ចឹងទៀត!
!

ក៖ ហ្ន៎កាងម៉ងហោមីង??

ខ៖ ហើយអត់ អត់ស្រក់ទឹកភ្នែកមួយដំណក់សោះ
ហើយទៅអូតគេនៅសាលារៀនហ្នឹងយកទឹកមាត់ជូត ធ្វើទឹកភ្នែក។

ក៖សុទ្ធតែអ៊ីចឹងទៀត!!

ខ៖ នឹកឃើញខ្មាសខ្លួនទៀតហ៎ ពេលអញ្ចឹង ដើរអូតគេថាហ៊ី
តែតាអញស្លាប់ហើយអត់អោយអាណាទៅស៊ីបបរបុណ្យទេ។

ក៖សុទ្ធតែអញ្ចឹងទៀត។

ខ៖ ហ៊ីមើលអញយំហ៊ិ!! តែតាមការពិតយកទឹកមាត់ជូតទឹកភ្នែកសោះ ធ្វើទឹកភ្នែក។

ក៖ នៅក្មេងអត់ដឹងអ្នកមីងណោះ?

ខ៖ហ៊ី!!

ក៖ មើលមានអីចាំពីតាទៀតទេ?

ខ៖ អត់ទេបានហើយ ព្រោះអីគាត់ស្លាប់ហើយ!!

ក៖ មានតែប៉ុណ្ណឹង។

ខ៖
មីងដល់ពេលនេះអើរចូលដល់ខាងឪពុកវិញម្តងតើយាយខាងឪពុកគាត់ឈ្មោះយាយអីគេវិញ
មីង?

ខ៖ ឈ្មោះយាយយ៉ែម។

ក៖ យាយយ៉ែម??

ខ៖ ចា!!

ក៖ មីងចាំត្រកូលយាយទេ?

ខ៖អត់។

ក៖មីងកើតទាន់គាត់ទេ?

ខ៖ អត់។

ក៖ អត់ដែរ !!តែដែលឪគាត់ប្រាប់ថាគាត់អ្នកស្រុកមកពីណាទេ?

ខ៖ នៅកំពង់ធំ កំពង់ភ្នំ!!កំពង់ធំអីក៏កំពង់ភ្នំទេ !! កំពង់ភ្នំ។

ក៖ នៅឯណាវិញទៅ?

ខ៖ នៅខាងអ្នកលឿងហ្នឹង កំពង់ភ្នំហី!!

ក៖ ហ្នឹងហើយកំពង់ភ្នំ បើកំពង់ធំនៅខាងខេត្តវិញហើយ!!

ខ៖ ហ្នឹងហើយ កំពង់ភ្នំ។

ក៖ ចាមិញយាយហីតា?

ខ៖ យាយយាយ។

ក៖ យាយ!!ដែលប៉ាប្រាប់ថាគាត់ម៉េចៗអីទេមីង?

ខ៖ អត់ទេគាត់អត់ដែរសូវទេ និយាយ ក៏ដោយ អត់ដែលទាំងឃើញមុខផង
អត់ទាំងសួរនាំផងហ៊ីថាយាយទៅណា យាយ ធ្វើអីធ្វើអីអត់!!

ក៖ អត់ដែរ!!

ខ៖ ដល់តែដឹងក្តីឡើងបងប្អូនជីដូនមួយ គេថាជីដូនមួយថាជីដូនមួយនឹងគេទៅ។

ក៖ចា៎!!

ខ៖ គេថាបង្កើតបង្កើតនឹងគេទៅ។

ក៖ ដឹងតែប៉ុណ្ណឹងទេហេ?

ខ៖ ចា៎អោយ!!

ក៖ ហើយភាគច្រើនពួកគាត់អ្នករកស៊ីអីគេដែរ?

ខ៖ យាយញ៉ុមច្រើនតែធ្វើដំនាំដាំស្រូវដាំអីហ្នឹង ធ្វើស្រូវធ្វើអីហ្នឹង។

ក៖ចា៎!!

ខ៖មើលគោស្រូវ ដំនាំពេលមុនរបស់គាត់ហ្នឹង។

ក៖ ហ្ន៎អ្នកស្រុកពេលមុនច្រើនតែធ្វើអញ្ចឹងណោះ?

ខ៖ ហ្នឹងហើយ គោ ពោត ។

ក៖ចា៎!!

ខ៖ ពពាយអីបន្តិចបន្តួចរបស់គាត់ហ្នឹង!!

ក៖ ដាំអីអ៊ីចឹងទៅម៉ងទៅ?

ខ៖ ចា៎!!

ក៖ អ៊ីចឹងអ្នកមីងសំរាប់ចូលដល់តាវិញម្តង
តើតារបស់!!តើឪរបស់ឪពុករបស់អ្នកមីងគាត់ឈ្មោះអីគេវិញតា?

ខ៖ ឈ្មោះជួប ។

ក៖ តាជួប!!ហ្នឹងហើយអ្នកមីងបានយកត្រកូលមីងដាក់ដល់សព្វថ្ងៃហ្នឹង!!

ខ៖ ចា!!

ក៖ មីងកើតទាន់តាជួបទេ?

ខ៖ ទាន់។

ក៖ ចា!អីចឹងសុទ្ធតែទាន់តាទាំងសងខាងអត់ទាន់តែយាយទេ!!

ខ៖ ទាន់!!អត់យាយទាំងសងខាង។

ក៖ យាយដឹងទេ ថាគាត់អ្នកស្រុកមកពីណាតា?

ខ៖ ស្រុកនៅហ្នឹងម៉ង!! បងប្អូនគាត់បង្កើតហ្នឹង។

ក៖ ហ្ហ!!អីចឹងនៅនេះ!!

ខ៖ នៅជាមួយគ្នាហ្នឹង ស្វាយរលំ។

ក៖ ស្វាយរលំហ្នឹងដែរ!!

ខ៖ ទឹកវល់!!

ក៖ ចា!អីចឹងមីងសំរាប់!!អូមែនគាត់បងប្អូននឹងគ្នា!!

ខ៖ បង្កើត។

ក៖ហ្នឹងហើយ។

ខ៖ ម៉ែហើយនឹងឪបងប្អូនជីដូនមួយ!!

ក៖ ចា អញ្ចឹងគាត់រកស៊ីអីគេដែរតា?

ខ៖ គាត់ដូចគ្នា គាត់ធ្វើស្រូវ ធ្វើពោតធ្វើអីមើលគោមើលអីនៅចំការគាត់ហ្នឹងតែប៉ុណ្ណឹង ធ្វើតែចំការគាត់រែងៗអញ្ចឹងទៅ ហើយដើរទៅ តាមតែគាត់ហ្នឹង!!

ក៖ ចា៎មើលមីងរៀបរាប់ពីតាបន្តិចមើល តើចាំអីគេខ្លះពីតារៀបរាប់អោយអស់មក!!

ខ៖ ហ៊ីអានិតអាសូរគាត់ណាស់ដល់ពេលគាត់ចាស់ទៅហ៊ា!! គាត់ដើរ ជើងគាត់អាឈឺហ្នឹងហ្ន៎ គាត់ដើរឡើងកាងដឹកដៃញ៉ុមទៅហើយ
ថ្ងៃណាដល់ពេលគាត់អត់ពីយាយទៅដល់គាត់បែកៗគ្នាអស់គេទៅធ្វើការ
ធម្មតាគេមានប្ដីប្រពន្ធ គេមិនត្រូវទៅរកចិញ្ចឹមប្ដីប្រពន្ធគេ
ញ៉ុមទៅនៅតែជាមួយគាត់ហ្នឹងទៅហើយ
ជួនណាលទៅដល់កន្លែងណោះកន្លែងចុងតាម៉ៅយើងនេះទៅអ៊ីចឹងទៅអ៊ី
ចែកឹមអ៊ីវ៉ាន់ហ្នឹងគាត់អោយអង្ករអោយអីទូលហ៊ា!ប្រហែល២គីឡូ២គីឡូ ទូលចង់បាក់ករងាប់ ដឹកដៃហើយមកដល់ គាត់ដាំបាយដាំអីញ៉ុមរត់រឹងរត់មកតែផ្ទះខាងម៉ែអ៊ីចឹងទៅ
ហើយដើរបានតែ២នាក់គាត់ហ្នឹង។

ក៖ ចុះពេល
ពេលគាត់នៅរស់គាត់នៅជាមួយឪពុកម្ដាយរបស់អ្នកមីងឬក៏នៅជាមួយអ្នកណាគេ?

ខ៖ គាត់នៅម្នាក់ឯង។

ក៖ គាតមានផ្ទះមួយម្នាក់ឯងអ៊ីចឹងទៅ?

ខ៖ មួយម្នាក់ឯងអ៊ំញ៉ុមអ៊ីវ៉ាន់នៅមុខគាត់អញ្ចឹងទៅគាត់ទៅធ្វើនៅកណ្ដាលមីងញ៉ុមនៅចុងទៅ
មីងញ៉ុមនៅចុង!!

ក៖ តែអត់នៅជាមួយកូន??

ខ៖ អត់ទេ ឃើញផ្ទះគាត់ផ្ទះឈឺប្រកស្លឹក។

ក៖ តែគាត់ស្លាប់មូលហេតុអីមីងចាំទេ?

ខ៖ គាត់ស្លាប់កាលបែកអាពត។

ក៖ ពេលបែកហើយ!!

ខ៖ គេយកដឹកថាញ៉ុមទៅសំប៉ាន់គាត់នៅម្នាក់ឯង ថាគេហៅទៅគាត់អត់ទៅទេ
គាត់សុខចិត្តនៅចាំមើលដីគាត់ដល់តែពេលគាត់ឈឺគាត់ទៅនៅពេទ្យជ័យជំនះនេះ
នៅខាងមុខមន្ទីរពេទ្យហ្នឹង
គេក៏លើកដាក់ឡានទៅយកទៅចាក់ចោលទៅមិនដឹងសពនៅទីណា??

ក៖ ហ៊ឺ!!អញ្ចឹងគាត់ស្លាប់នៅហ្នឹងទៅ?

ខ៖ អត់ដឹងទាំងអស់គ្នា!!គាត់ស្លាប់នៅហ្នឹង។

ក៖តែអត់ដឹងគេដឹកយកទៅណា?

ខ៖ អត់ដឹងទៅណា។

ក៖ ចាក់ចោលមើលតែចាក់អីគេហើយមីង មនុស្ស!!

ខ៖ គេដឹកទាំងឡាន មិនមែនម្នាក់ទេ គេដឹកទាំងឡានហ្ន៎!!

ក៖ស្លាប់ច្រើនហេ?

ខ៖
ស្លាប់ច្រើនចុះអ្នកក្នុងមន្ទីរពេទ្យផងហើយដល់គាត់ស្លាប់នៅខាងមុខមន្ទីរពេទ្យហ្នឹងឮគេនិយាយថាគេលើកបោះដាក់ឡើងឡានបាត់ហើយ ប៉ុន្តែគេយកទៅចាក់ចោល
ប៉ុនថាទូលស្លែងនេះក៏មិនដឹងទៅណាណាទៀតក៏មិនដឹង!!

ក៖ ចាំតាថាគាត់កើតឆ្នាំសត្វអីគេវិញមីង?ចាំទេ?

ខ៖ គាត់ឆ្នាំ គោហេ!!ក៖ឆ្លូវ!!ខ៖ គាត់គោ។

ក៖ ចា!!មីងគាត់ស្លាប់ពេលឆ្នាំប៉ុន្មានវិញ មីងប្រាប់មិញ ប្រាប់ន្ទូវមិញ?

ខ៖ ៧៤(១៩៧៤)។

ក៖ ១៩៧៤ អ៊ីចឹងដូចបងប្អូនគាត់ដែរ?

ខ៖ ហ្នឹងហើយ ព្រោះអីនៅជំនាន់ហ្នឹងនៅណេះក៏មិនទាន់បែកនៅណោះក៏ស្លាប់
ដល់ហើយគាត់ ណោះក៏ស្លាប់ណេះក៏ស្លាប់
គេលើកទៅក្រោមណោះក៏ធ្វើបុណ្យនៅណោះទៅ។

ក៖ ចា!!ហើយតាស្លាប់អាយុប៉ុន្មានមីងចាំទេ?

ខ៖ ហ្ហ!អត់បានដឹង។

ក៖តែគ្រាន់តែដឹងថាគាត់ស្លាប់ឆ្នាំ១៩៧៤!!

ខ៖ ចា!ស្លាប់ដំនាលគ្នា។

ក៖ចា!មីងមានអីចង់ប្រាប់ពីតាទៀតទេ?ចាំអនុស្សាម៉ាវអីជាមួយតាទៀតទេ?

ខ៖ អត់ទេ ។

ក៖
អស់ហើយហេ?អីចឹងមីងសំរាប់បងប្អូនណាណារបស់មីងមានអ្នកណាគេធ្លាប់ទៅនៅប្រទេស
ក្រៅអីអត់?

ខ៖ អត់មានទេ!!

ក៖ទៅថៃទៅអី ធ្វើការអីអត់ទេហេ?

ខ៖ មានតែជីដូនមួយ។

ក៖ គេទៅធ្វើការនៅឯណាវិញ?

ខ៖ គេមានប្តីប្រពន្ធគេនៅហ្នឹង។

ក៖ នៅទៅថៃហ្នឹងហេ?

ខ៖ ហ្នឹងហើយ គេលក់បង្អែមនៅគេហៅអាម៉េចមីអូន??

(ក្ងន)៖ ដងទង់ គេលក់បង្អែម ហ្ហ!គេចំនេញហ្ហ!!

ក៖ នៅតែមិនទាន់ចូលដល់ដីថៃណាហ៊ី?

ខ៖ នៅក្នុងដងទង់នៅ!!អត់ទេអត់ទាន់ទៅដល់ទេ អត់ដល់ថៃទេ នៅដងទង់កោះកុងនេះទេ!!

ក៖ហ្គ៎ៗ!!

ខ៖ បើទៅថៃហ្គ៎មានជីដូនមួយមួយទៅ!!

ក៖ចា៎!!

ខ៖ឥឡូវគេមានគ្រួសារនៅហ្នឹងគេអត់មកទេ ថ្ងៃមុនគេមកធ្វើពន្ធអោយម៉ែគេ
ដល់ពេលគេធ្វើហើយគេទៅ។

ក៖ ចា៎ហ្នឹងហើយ
អ៊ីចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍ដែលអ្នកមីងអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរ
បស់អ្នកមីងក៏ដូចជាដូនតារបស់បងប្អូនផងដែរ ចា៎អ៊ីចឹងអរគុណច្រើនណាស់អ្នកមីង!!

ខ៖ ចា៎។